# ដីមាស

# DEI MEAS

## ប្រព័ន្ធនៃការផ្លាស់ប្តូរឆ្ពោះទៅរកការអនុវត្តកសិកម្មអេកូឡូស៊ី

## បរិបទ

ការអនុវត្តកសិកម្មអេកូឡូស៊ីគឺជាផ្នែកដ៏សំខាន់មួយក្នុងការស្តារឡើងវិញនូវគុណភាពដី បង្កើនសារធាតុចិញ្ចឹម ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុខណៈពេលដែលលើកកម្ពស់ដោយផ្ទាល់ទៅលើសន្តិសុខស្បៀង និងជីវភាពរបស់កសិករ។

តាមរយៈការផ្លាស់ប្តូរឆ្ពោះទៅរកកសិ-អេកូឡូស៊ីកសិករខ្នាតតូចកំពុងចូលរួមចំណែកដោយផ្ទាល់ដល់ការស្តុកទុកកាបូនក្នុងដី និងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ទន្ទឹមនឹងនោះក៏ចូលរួមបង្កើនសេវាកម្មអេកូឡូស៊ី និងអត្ថប្រយោជន៍រួមជាច្រើនទៀតផងដែរ។

តែយ៉ាងណាក៏ដោយនៅពេលទទួលយកការអនុវត្តទាំងនេះ កសិករខ្នាតតូចតែងតែប្រឈមមុខនឹងភាពមិនច្បាស់លាស់ក្នុងរយៈពេលខ្លីផ្សេងៗ។ ការផ្លាស់ប្តូររបស់ពួកគាត់អាចចំណាយពេលច្រើនឆ្នាំ ដូចឆ្នេះហើយកសិករប្រហែលជាមិនប្រថុយនឹងការផ្លាស់ប្តូរដោយគ្មានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសទេ។

## ការសាកល្បង

ក្នុងក្របខ័ណ្ឌនៃគម្រោងASSET នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មបានអនុវត្តគំនិតផ្តួចផ្តើមសាកល្បងថ្មីមួយឈ្មោះដីមាសក្រោមការគាំទ្រពីក្រុមហ៊ុនស្មាតអាក្រ(SmartAgro) អង្គការស្វីសខន់ថាក់(Swisscontact) និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (CIRAD) ។

គំនិតផ្តួចផ្តើមសាកល្បងដីមាសមានគោលបំណងគាទ្រដល់ការផ្លាស់ប្តូរឆ្ពោះទៅរកកសិ-អេកូឡូស៊ីហើយកសិករខ្នាតតូចជាគោលដៅ។ ដីមាស មានសសរស្តម្ភចំនួន៣ ៖ ការផ្លាស់ប្តូរ ការកំណត់បរិមាណ យន្តការហិរញ្ញវត្ថុ។



| | |
|---|---|
| ឈ្មោះគម្រោង | ដីមាស (Golden Soil) |
| គម្រោង | ការផ្លាស់ប្តូរកសិអេកូឡូស៊ី និងប្រព័ន្ធសុវត្ថភាពចំណីអាហារក្នុងតំបន់អាស៊ីអាគ្នេយ៍ (ASSET) |
| ស្ថាបនិក | French Facility for Global Environment (FFEM) |
| ទីតាំង | ខេត្តបាត់ដំបង, ប្រទេសកម្ពុជា |
| ភ្នាក់ងារប្រតិបត្តិ | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ដៃគូរអភិវឌ្ឍន៍គម្រោង | ក្រុមហ៊ុនSmartAgro, អង្គការCIRAD និងអង្គការ Swisscontact |
| រយៈពេល | ២០២២ - ២០២៤ (០៣ ឆ្នាំ) |

## សសរស្តម្ភទាំង

១ ផ្តល់ប្រាក់លើកទឹកចិត្ត: ជួយគាទ្រដល់កសិករដើម្បីអាចសាកល្បងអនុវត្តកសិអេកូឡូស៊ីជាមួយនឹងប្រព័ន្ធផ្តល់ប្រាក់រង្វាន់ប្រកបដោយតម្លាភាព។

២ ការកំណត់បរិមាណ:អនុវត្តប្រព័ន្ធដែលមានប្រសិទ្ធភាពនិងច្បាស់លាស់ (MRV system) រួមជាមួយការតេស្តបច្ចេកវិទ្យាឆ្នៃប្រឌិតផ្សេងៗគ្នាដើម្បីកំណត់បរិមាណនៃការស្តុកទុកកាបូនក្នុងដី ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងផលប៉ះពាល់ និងអត្ថប្រយោជន៍រួម។

៣ ហិរញ្ញវត្ថុ:យន្តការហិរញ្ញវត្ថុដែលស្វែងរកទីផ្សារសម្រាប់ឥណទានដែលធានានូវគំរូអាជីវកម្មប្រកបដោយនិរន្តរភាព និងការចម្លងរបស់វា។

## ការផ្លាស់ប្តូរ

នៅពេលបានចុះឈ្មោះជាមួយគម្រោងដីមាស កសិករខ្នាតតូច ១) មានការសម្របសម្រួលទៅលើការប្រើប្រាសធាតុចូលនៃកសិអេកូឡូស៊ី(ពូជដំណាំគម្របដីឧបករណ៍និងម៉ាស៊ីនសមស្របនិងធាតុចូលផ្សេងៗទៀត) ដែលផ្តល់ដោយសហគមន៍កសិកម្ម និងក្រុមហ៊ុនឯកជននៅក្នុងតំបន់។ ២)ទទួលបានវគ្គបណ្តុះបណ្តាលនិងជំនួយបច្ចេកទេសដើម្បីធានាបាននូវការអនុវត្តកសិអេកូឡូស៊ីប្រកបដោយជោគជ័យ (ជម្រើស និងការគ្រប់គ្រងដំណាំគម្របដី ការបញ្ចេញបញ្ចូលទឹក បច្ចេកទេសដាំលើកាកសំណល់ស្រស់ ពិពិធកម្មដំណាំចម្រុះ ។ល។) ដែលជួយគាំទ្រពីដៃគូរពាក់ព័ន្ធដូចជាមន្ទីកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តបាត់ដំបង ក្រុមការងារគម្រោង(WAT4CAM) ក្រុមការងារមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មអភិរក្សកម្ពុជា (CARDEC) ។ល។

ការផ្ទៀងផ្ទាត់នៃការអនុវត្តដោយជោគជ័យនឹងធ្វើឡើងតាមរយៈការត្រួតពិនិត្យផ្ទាល់និងការវាយតម្លៃដោយការដាក់ពិន្ទុនៅចុងនៃរដូវកាលដាំដុះដំណាំ។ នៅពេលការវាយតម្លៃបានផ្ទៀងផ្ទាត់ត្រឹមត្រូវ ប្រាក់លើកទឹកចិត្តនឹងចែកជូនកសិករ ។

## ការកំណត់បរិមាណ

អំឡុងពេលសាកល្បងគម្រោងផលប៉ះពាល់នៃការផ្លាស់ប្តូរការអនុវត្តទៅលើកាបូនដី (ការស្តុកទុកកាបូន ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់និងសេវាកម្មអេកូឡូស៊ី(ការប្រើប្រាស់សារធាតុចិញ្ចឹមប្រកបដោយប្រសិទ្ធភាព កាត់បន្ថយការហូរច្រោះដី បង្កើនជីវចម្រុះ ។ល។ ) ត្រូវបានវាស់វែងដោយប្រើឧបករណ៍មួយចំនួនដូចជាBiofunctool®[1], Infra-red spectroscopy, គំរូកាបូន(Modelling) និងរូបភាពផ្កាយរណប។ ឧបករណ៍ទាំងអស់នេះគឺបានកាលីប្រេត តេស្ត និងធ្វើការប្រៀបធៀបដើម្បីទទួលបាននូវប្រព័ន្ធMRVមួយដែលមានប្រសិទ្ធភាពខ្ពស់ស្របទៅតាមបរិបទកម្ពុជា(តំបន់ត្រូពិក កសិករខ្នាតតូច)។

## យន្តការហិរញ្ញវត្ថុ

បរិមាណផលប៉ះពាល់និងអត្ថប្រយោជន៍រួមនៃកសិអេកូឡូស៊ីបានផលិតជា "លទ្ធផលដែលអាចវាស់វែងបាន"ដែលនាំអោយយើងអាចមានលទ្ធភាពក្នុងការរកទីផ្សារដើម្បីស្វែងរកហិរញ្ញប្បទានផ្សេងៗបានដូចជាឥណទានកាបូន ឥណទានអេកូឡូស៊ី គុណភាពចំណីអាហារ ការចូលរួមចំណែកថ្នាក់ជាតិ (NDC) គោលដៅអព្យាក្រឹតនៃការធ្លាក់ចុះគុណភាពដីអ្នកវិនិយោគដែលចាប់អារម្មណ៍ក្នុងការផ្តល់ហិរញ្ញប្បទានដល់កសិករខ្នាតតូចក្នុងការផ្លាស់ប្តូរទៅរកសិកម្មអេកូឡូស៊ី។

## លទ្ធផល

នៅចុងបញ្ចប់នៃគម្រោងសាកល្បងនេះសសរស្តម្ភទាំង៣(ការផ្លាស់ប្តូរការកំណត់បរិមាណនិងយន្តការហិរញ្ញវត្ថុ)នឹងត្រូវបានបង្កើតឡើងដែលត្រួតពិនិត្យដោយគណកម្មាធិការតម្រង់ទិសនិងដឹកនាំដោយនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មក្នុងការផ្តល់ប្រាក់លើកទឹកចិត្តដល់កសិករខ្នាតតូចឆ្ពោះទៅរកកសិ-អេកូឡូស៊ីនិងមានការទទួលស្គាល់ពីអន្តរជាតនៃការផ្លាស់ប្តូរនេះតាមរយៈផលប៉ះពាល់ និងអត្ថប្រយោជន៍រួម។

## សមិទ្ធផល

- បង្កើនផលិតភាពនិងប្រាក់ចំណូលប្រកបដោយនិរន្តរភាព
- បង្កើនភាពធន់របស់កសិករខ្នាតតូចចំពោះការប្រែប្រួលអាកាសធាតុ
- រក្សា និងបង្កើនជីជាតិដី ធនធានទឹក និងសេវាកម្មអេកូឡូស៊ីផ្សេងៗទៀត
- ការប្រមូលកាបូនដី ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ផែនទីទាំងពីរទីតាំងនៃគម្រោងដីមាស






